**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

លេខ ០៤៧ [illegible] ពម

ថ្ងៃ ព្រហស្បតិ៍ ៦ រោច ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង

## ស្តីពីការប្រើប្រាស់ឈ្មោះដែនជាតិ (Domain Name) ".kh"

ក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ អង្គការ សមាគម ដែលធ្វើការលើវិស័យព័ត៌មាន និងសោតទស្សន៍ទាំងអស់ជ្រាបថា ក្រសួងសង្កេតឃើញថានៅមានការស្នើសុំប្រកបអាជីវកម្មអនឡាញលើវិស័យព័ត៌មាន និងសោតទស្សន៍ ដោយប្រើប្រាស់ឈ្មោះដែនបរទេស។ អនុលោមតាមអនុក្រឹត្យលេខ ២៨៧ អនក្រ.បក ចុះ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ឈ្មោះដែនជាតិនៅក្នុងប្រព័ន្ធអ៊ីនធឺណិត បានកំណត់ឱ្យនីតិបុគ្គលទាំងអស់ ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រើប្រាស់ឈ្មោះដែនជាតិ។

ដើម្បីបង្កើតអត្តសញ្ញាណផ្លូវការរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល នៅក្នុងប្រព័ន្ធអ៊ីនធឺណិត បង្កើនភាពជឿជាក់លើពាណិជ្ជនាមដល់អតិថិជន ឬដៃគូសហការ ជាពិសេសផ្តល់ភាពងាយស្រួលសម្រាប់ការស្វែងរកតាមប្រព័ន្ធអ៊ីនធឺណិត ក្រសួងសូមលើកទឹកចិត្ត ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ អង្គការ សមាគម ដែលធ្វើការលើវិស័យព័ត៌មាន និងសោតទស្សន៍ដូចខាងក្រោម៖

១- សម្រាប់ការស្នើសុំថ្មីក្នុងការប្រកបអាជីវកម្មលើវិស័យព័ត៌មាន និងសោតទស្សន៍ សូមប្រើប្រាស់ឈ្មោះដែនជាតិ (Domain Name) ".kh"។

២- សម្រាប់ម្ចាស់អាជីវកម្មដែលកំពុងប្រើប្រាស់ឈ្មោះដែនបរទេស សូមធ្វើការផ្លាស់ប្តូរទៅប្រើប្រាស់ឈ្មោះដែនជាតិ ".kh" ដោយទុករយៈពេលរហូតដល់ដំណាច់ឆ្នាំ២០២៥។

៣- សម្រាប់ម្ចាស់អាជីវកម្មដែលទទួលបានប្រកាសអនុញ្ញាតប្រកបអាជីវកម្មគេហទំព័រ ប៉ុន្តែផ្សព្វផ្សាយព័ត៌មានតាមបណ្តាញទំនាក់ទំនងសង្គម សូមរួសរាន់ពិនិត្យឡើងវិញយ៉ាងយូរដំណាច់ខែមីនា ឆ្នាំ២០២៥។ ករណីនៅតែមិនដំណើរការ ក្រសួងនឹងចាត់វិធានការបន្ត។

៤- ការចុះឈ្មោះស្នើសុំប្រើប្រាស់ឈ្មោះដែនជាតិ តាមរយៈគេហទំព័រ សេវាចុះឈ្មោះដែនជាតិ .kh (https://www.domain.gov.kh/)។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ម្ចាស់ប្រព័ន្ធផ្សព្វផ្សាយ អង្គការ សមាគម ដែលធ្វើការលើវិស័យព័ត៌មាន និងសោតទស្សន៍ទាំងអស់ជ្រាប និងចូលរួមអនុវត្ត។

អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building62, Monivong BLVD,Sangkat Srah Chork, Khan Daun Penh, PhnomPenh E-mail:information@info.gov.kh